# ការទាមទារតាមផ្លូវតុលាការ
# ~ផ្អែកលើករណីសិក្សាស្តីពីការរំលាយកិច្ចសន្យា~

JICA Legal Adviser SHINODA, YOICHIRO

# មាតិកា

ទី1 សំណុំរឿង1
1 ការទទួលរឿងក្តី
2 ការធ្វើបណ្តឹង
3 ការបន្តចូលកាលបរិច្ឆេទ
4 សាលក្រម

ទី2 សំណុំរឿង2
1 ការទទួលរឿងក្តី
2 ការធ្វើបណ្តឹង
3 ការបន្តចូលកាលបរិច្ឆេទ
4 សាលក្រម

ទី3 សំណុំរឿង3
1 ការទទួលរឿងក្តី
2 ការធ្វើបណ្តឹង
3 ការបន្តចូលកាលបរិច្ឆេទ
4 សាលក្រម

# ទី1 សំណុំរឿង1

មានអ្នកលក់ X និង អ្នកទិញ Y ហើយកម្មវត្ថុនៃការលក់ទិញ គឺ ដី និង ផ្ទះ (L) ហើយថ្លៃលក់ទិញ គឺចំនួន១០ម៉ឺនដុល្លារ។ ចំពោះវិធីនៃការបង់ប្រាក់គូភាគីបានចែងនៅក្នុងកិច្ចសន្យា។ ពោលគឺ ចុងចម្លើយបានបង់ប្រាក់កក់ចំនួន៣ម៉ឺនដុល្លារនៅថ្ងៃចុះកិច្ចសន្យា (ថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៧) ហើយ ប្រាក់ដែលនៅសល់ចំនួន៧ម៉ឺនដុល្លារ ត្រូវតែបង់នៅពេលដែល X ធ្វើការផ្ទេរកម្មសិទ្ធិលើដី និងផ្ទះ(L) មកឲ្យ Y រួចរាល់ (ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៧)។ កិច្ចសន្យាលក់ទិញនោះគូភាគីបានធ្វើជាលិខិតយថាភូត និងបានចុះបញ្ជីផ្ទេរកម្មសិទ្ធិពី X ទៅ Y រួចរាល់ផងដែរ។ ប៉ុន្តែ Y មិនបានបង់ប្រាក់ដែលនៅសល់ចំនួន៧ម៉ឺនដុល្លារឲ្យទៅ X ទេ។

<u>បើសិនជា X ចង់យកដី និង ផ្ទះ (L) មកវិញ តើត្រូវធ្វើដូចម្តេច?</u>

→ X បានពឹងពាក់ និងពិគ្រោះជាមួយមេធាវី។

# ទី1 សំណុំរឿង1

<រូបភាព>



# 1 ការទទួលរឿងក្តី(សំណុំរឿង1)

ប្រសិនបើអ្នកបានទទួលរឿងក្តីដូចករណីនេះ! តើត្រូវធ្វើយ៉ាងដូចម្តេច?



# 1 ការទទួលរឿងក្តី(សំណុំរឿង1)

ជាដំបូង សូមបញ្ជាក់អំពីគោលបំណងរបស់អតិថិជន!

គោលបំណងរបស់អតិថិជនគឺ

ចង់បានដី និងផ្ទះ (L) មកវិញ!



# 1 ការទទួលរឿងក្តី(សំណុំរឿង1)

បើ X ចង់បានដី និង ផ្ទះ (L) មកវិញ តើ X គួរធ្វើយ៉ាងដូចម្តេច?

គួររំលាយកិច្ចសន្យារវាង X និងY!

(ក្រមរដ្ឋប្បវេណី មាត្រា៤១១)
១-ការរំលាយកិច្ចសន្យានាំឲ្យគូភាគីរួចផុតពីករណីយកិច្ចក្នុងកិច្ចសន្យា លើកលែងតែករណីយកិច្ចសងការខូចខាត។
២-ភាគីដែលបានទទួលតាវកាលិកនៃកិច្ចសន្យាតែមួយភាគ ឬ ទាំងអស់ ត្រូវមានករណីយកិច្ចសងតាវកាលិកនោះទៅភាគីម្ខាងទៀត ដើម្បីឲ្យភាគីនោះទទួលបដិទានឡើងវិញ ដោយសារការរំលាយ។ ក្នុងករណីដែលភាគីទាំងសងខាង មានករណីយកិច្ចធ្វើបដិទានទៅវិញទៅមក ករណីយកិច្ចទាំងនោះត្រូវអនុវត្តនៅពេលជាមួយគ្នា។

# 1 ការទទួលរឿងក្តី(សំណុំរឿង1)

ការរំលាយកិច្ចសន្យារវាង X និង Y




ករណីយកិច្ចធ្វើបដិទានឡើងវិញ
(ក្រមរដ្ឋប្បវេណី មាត្រា៤១១.កថា.ទី២)

# 1 ការទទួលរឿងក្តី(សំណុំរឿង1)

មុនការបង្ហាញឆន្ទៈរំលាយកិច្ចសន្យា តើ X មានអ្វីត្រូវធ្វើសិនដែរ ឬ ទេ?

ក្នុងករណីនៃរឿងក្តីនេះ X ចាំបាច់ត្រូវកំណត់អំឡុងពេលសមរម្យហើយដាស់តឿនទៅ Yសិន។

(ក្រមរដ្ឋប្បវេណី មាត្រា៤០៧)

ភាគីម្ខាងនៃកិច្ចសន្យាអញ្ញមញ្ញអាចរំលាយកិច្ចសន្យាបានភ្លាមៗ ក្នុងករណីដែលភាគីម្ខាងទៀតបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ។

(ក្រមរដ្ឋប្បវេណី មាត្រា៤០៨ កថា.ទី១ ចំណុច ក. :ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ)

ភាគីម្ខាងបានដាស់តឿនភាគីម្ខាងទៀតដែលមិនបានអនុវត្តកាតព្វកិច្ច តាមពេលកំណត់ ដោយកំណត់អំឡុងពេលសមរម្យដើម្បីអនុវត្តកាតព្វកិច្ច ហើយកាតព្វកិច្ចមិនត្រូវបានអនុវត្តក្នុងអំឡុងពេលនោះ។

# 1 ការទទួលរឿងក្ដី(សំណុំរឿង1)

ការដាស់តឿន

ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៧



បង់ប្រាក់ដែលនៅសល់
ចំនួន៧ម៉ឺនដុល្លារឲ្យបាន
ត្រឹមចុងខែនេះមក!



# 1 ការទទួលរឿងក្តី(សំណុំរឿង1)

ទោះបីជាថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ បានមកដល់ហើយក៏ដោយ ក៏ Y មិនទាន់បានបង់ប្រាក់ចំនួន៧ម៉ឺនដុល្លារដែរ ហេតុនេះ X បានសម្រេចថាធ្វើការបង្ហាញឆន្ទៈរំលាយកិច្ចសន្យានេះ។

តើ X គួរធ្វើការបង្ហាញឆន្ទៈដោយរបៀបណា?

(ក្រមរដ្ឋប្បវេណី មាត្រា៤០៩)

១-ភាគីម្ខាងដែលមានសិទ្ធិរំលាយ អាចរំលាយកិច្ចសន្យា ដោយបង្ហាញឆន្ទៈរំលាយចំពោះភាគីម្ខាងទៀតបាន។ ការបង្ហាញឆន្ទៈរំលាយនេះអាចធ្វើឡើងក្រៅតុលាការបាន (មិនតម្រូវឲ្យមានអន្តរាគមន៍របស់តុលាការនោះទេ)។

# 1 ការទទួលរឿងក្តី(សំណុំរឿង1)

ការបង្ហាញឆន្ទៈរំលាយ

- មិនចាំបាច់ធ្វើតាមទម្រង់របស់តុលាការទេ។
- អាចធ្វើការបង្ហាញឆន្ទៈនៅក្រៅតុលាការបាន។

ឲ្យតែបានបង្ហាញឆន្ទៈអំពីការរំលាយទៅដល់ភាគីម្ខាងទៀត ទោះបីជាធ្វើឡើងដោយផ្ទាល់មាត់ ឬ តាមរយៈក្រដាស ឬ តាមអ៊ីម៉ែលក៏បានដែរ។

ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៧



ខ្ញុំនឹងរំលាយកិច្ចសន្យា
លក់ទិញដី និង ផ្ទះ(L)!



# 1 ការទទួលរឿងក្តី(សំណុំរឿង1)

ការបង្ហាញឆន្ទៈរំលាយ

ពាក្យបណ្តឹង

ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ

ដើមចោទ X ទាមទារឲ្យតុលាការចេញសាលក្រមចំពោះចុងចម្លើយ Y ដែលបញ្ជាក់អំពីការរំលាយកិច្ចសន្យាលក់ទិញដី និង ផ្ទះ(L) រវាងX និងY ចុះថ្ងៃទី១ ខែឧសភា ឆ្នាំ ២០១៧ ។





# 1 ការទទួលរឿងក្តី(សំណុំរឿង1)

ការឆ្លើយតបរបស់ភាគីម្ខាងទៀតY ចំពោះការរំលាយកិច្ចសន្យា (ករណី1)

Y បានទទួលយកការរំលាយកិច្ចសន្យា ហើយព្រមទទួលយកប្រាក់កក់ចំនួន៣មុឺនដុល្លារពី X និងបានសងការចុះបញ្ជីលើដី និងផ្ទះ(L)ឲ្យទៅ X វិញ។




→ ប្រសិនបើមិនចង់មានជម្លោះជាមួយភាគីម្ខាងទៀតទេ ភាគីអាចដោះស្រាយជម្លោះដោយការរំលាយកិច្ចសន្យានៅក្រៅផ្លូវតុលាការបាន។

# 1 ការទទួលរឿងក្តី(សំណុំរឿង1)

ការឆ្លើយតបរបស់ភាគីម្ខាងទៀត Y ចំពោះការរំលាយកិច្ចសន្យា (ករណី2)

Y មានវិវាទចំពោះការបង្ហាញឆន្ទៈរំលាយកិច្ចសន្យារបស់X




មិនប្រគល់
ទៅវិញដាច់
ខាត !

→ ប្រសិនបើភាគីម្ខាងទៀតមានវិវាទ ដូច្នេះ មានលទ្ធភាពខ្ពស់ដែលនឹងដោះស្រាយដោយសាលក្រម ឬ សាលដីការបស់តុលាការ។

# 1 ការទទួលរឿងក្តី(សំណុំរឿង1)

ការទទួលរឿងក្តី

↓

ការដាស់តឿន (ជាធម្មតា ធ្វើជាលិខិតលាយលក្ខណ៍អក្សរ)

↓

ការបង្ហាញឆន្ទៈរំលាយ (ជាធម្មតា ធ្វើជាលិខិតលាយលក្ខណ៍អក្សរ)

↓

ការចរចាជាមួយនឹងភាគីម្ខាងទៀត

↓ មិនអាចដោះស្រាយដោយការចរចារ → ↓ <u>ឈានទៅការរៀនចំពាក្យបណ្តឹង</u>

↓ បានដោះស្រាយដោយការចរចា → ↓ ការបញ្ចប់រឿងក្តី

# 2 ការធ្វើបណ្តឹង(សំណុំរឿង1)

ជាដំបូង សូមគិតអំពីខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ!

គោលបំណងរបស់អតិថិជនគឺ

ចង់បានដី និង ផ្ទះ (L) ត្រឡប់មកវិញ!



# 2 ការធ្វើបណ្តឹង(សំណុំរឿង1)

សាកគិតឲ្យបានលម្អិតអំពីខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ!



ចង់បានដី និង ផ្ទះ(L)ត្រឡប់មកវិញ!

① ខ្ញុំចង់ឲ្យសងការកាន់កាប់ដី និង ផ្ទះ (L) ត្រឡប់មកវិញ!

② ខ្ញុំចង់ឲ្យសងកម្មសិទ្ធិលើដី និង ផ្ទះ (L) !!

→ ជារួម ខ្ញុំចង់ឲ្យសងការចុះបញ្ជីកម្មសិទ្ធិត្រឡប់មកខ្ញុំវិញ!!!

# 2 ការធ្វើបណ្ដឹង(សំណុំរឿង1)

សាកគិតឲ្យបានលម្អិតអំពីខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ(រូបភាព)

① ខ្ញុំចង់ឲ្យសងការកាន់កាប់ដី និង ផ្ទះ(L) ត្រឡប់មកវិញ

ដី និង ផ្ទះ(L)



# 2 ការធ្វើបណ្តឹង(សំណុំរឿង1)

សាកគិតឲ្យបានលម្អិតអំពីខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ(រូបភាព)

② ខ្ញុំចង់ឲ្យសងកម្មសិទ្ធិលើដី និង ផ្ទះ(L)=ចង់ឲ្យសងការចុះបញ្ជី





ការចុះបញ្ជី





･ចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ?
･ចុះបញ្ជីអំពីការលុបការចុះ
បញ្ជី អំពីការផ្ទេរកម្មសិទ្ធិ?

# 2 ការធ្វើបណ្តឹង(សំណុំរឿង1)

(ប្រកាសអន្តរក្រសួងស្តីពី ការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមរដ្ឋប្បវេណី មាត្រា ៣១ ៖ ពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីការផ្ទេរកម្មសិទ្ធិ)

ខ- មូលហេតុ និងកាលបរិច្ឆេទណាមួយដូចខាងក្រោម៖

- ការលុបចោលកិច្ចសន្យា
- ការរំលាយកិច្ចសន្យា
- ការព្រមព្រៀងគ្នារំលាយកិច្ចសន្យា
- មូលហេតុផ្សេងទៀតដែលមានចែងក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត

ដោយសារតែសំណុំរឿង១ ត្រូវនឹងចំណុចនេះ ដូច្នេះ នឹងត្រូវចុះបញ្ជី អំពីការលុបចោលការចុះបញ្ជី

# 2 ការធ្វើបណ្ដឹង(សំណុំរឿង1)

សាកសរសេរឲ្យបានលម្អិតអំពីខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ!

① អំពីការសងការកាន់កាប់លើដី និង ផ្ទះ(L)ត្រឡប់មកវិញ
"បង្គាប់ឲ្យចុងចម្លើយ Y ចុះចេញពីដី និង ផ្ទះ (L) ហើយប្រគល់ទៅឲ្យដើមចោទដោយមូលហេតុរំលាយកិច្ចសន្យា"

② អំពីការសងកម្មសិទ្ធិលើដី និង ផ្ទះ (L)=អំពីការសងការចុះបញ្ជីត្រឡប់មកវិញ
"បង្គាប់ឲ្យចុងចម្លើយ Y ធ្វើនីតិវិធីចុះបញ្ជី អំពីការលុបការចុះបញ្ជីផ្ទេរកម្មសិទ្ធិ ដែលបានចុះបញ្ជីលេខ ○○ ដោយមូលហេតុរំលាយកិច្ចសន្យាចុះថ្ងៃទី១ ខែមករា ឆ្នាំ២០១៧"

# 2 ការធ្វើបណ្ដឹង (សំណុំរឿង 1)

បន្ទាប់មក សូមគិតអំពីមូលហេតុនៃការទាមទារ !




សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត

ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ

មូលហេតុនៃការទាមទារ ៖ អង្គហេតុដែលត្រូវនឹងលក្ខខណ្ឌគតិយុត្ត ដែលចាំបាច់ដើម្បីបង្កើតនូវសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត

# 2 ការធ្វើបណ្តឹង(សំណុំរឿង1)




សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត

ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ

តើដើមចោទត្រូវអះអាងអំពីអង្គហេតុបែបណា?

សិទ្ធិទាមទារឲ្យធ្វើបដិទានឡើងវិញផ្អែកតាម
ការរំលាយកិច្ចសន្យា (ក្រមរដ្ឋប្បវេណី មាត្រា៤១១ កថា.ទី២)

① ការចុះចេញហើយប្រគល់ដី និង ផ្ទះ (L)
② ការលុបការចុះបញ្ជីផ្ទេរកម្មសិទ្ធិ

# 2 ការធ្វើបណ្តឹង(សំណុំរឿង1)

មូលហេតុនៃការទាមទាររបស់សិទ្ធិទាមទារឲ្យធ្វើបដិទានឡើងវិញផ្អែកតាមការរំលាយកិច្ចសន្យា

លក្ខខណ្ឌ1 : ការបង្កើតកិច្ចសន្យាដើម (ក្រមរដ្ឋប្បវេណី មាត្រា៤០៧ ជាដើម )

លក្ខខណ្ឌ2 : បានផ្តល់តាវកាលិក (ប្រាក់) ជាអាទិ៍ ដោយផ្អែកតាមកិច្ចសន្យា(លក្ខខណ្ឌ1) ( ក្រមរដ្ឋប្បវេណី មាត្រា៤១១ កថា.ទី២)

លក្ខខណ្ឌ3: អង្គហេតុដែលជាមូលហេតុបង្កើតសិទ្ធិរំលាយ = ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ (ក្រមរដ្ឋប្បវេណី មាត្រា៤០៧ មាត្រា៤០៨)

លក្ខខណ្ឌ4: ការបង្ហាញឆន្ទៈថា រំលាយកិច្ចសន្យា(លក្ខខណ្ឌ1) (ក្រមរដ្ឋប្បវេណី មាត្រា៤០៩ កថា.ទី១)

# 2 ការធ្វើបណ្តឹង(សំណុំរឿង1)



# 2 ការធ្វើបណ្តឹង(សំណុំរឿង1)

មូលហេតុនៃការទាមទាររបស់សិទ្ធិទាមទារឲ្យធ្វើបដិទានឡើងវិញផ្អែកតាមការរំលាយកិច្ចសន្យា

លក្ខខណ្ឌ1:នៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៧ អ្នកលក់ X និងអ្នកទិញ Y បានបង្កើតកិច្ចសន្យាលក់ទិញ ដោយធ្វើជាលិខិតយថាភូត ដែលមានខ្លឹមសារថា លក់ដី និង ផ្ទះ (L) ក្នុងតម្លៃ ១០ម៉ឺនដុល្លារ។

លក្ខខណ្ឌ2:នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៧ X បានប្រគល់ដី និង ផ្ទះ (L) ហើយបានធ្វើការចុះបញ្ជីផ្ទេរកម្មសិទ្ធិទៅឲ្យ Y ។

# 2 ការធ្វើបណ្តឹង(សំណុំរឿង1)

លក្ខខណ្ឌ3-1៖ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៧ X បានដាស់តឿនទៅ Y ឲ្យបង់ប្រាក់ថ្លៃលក់ទិញដែលនៅខ្វះចំនួន៧ម៉ឺនដុល្លារ ឲ្យបានត្រឹមថ្ងៃចុងក្រោយនៃខែវិច្ឆិកា។

លក្ខខណ្ឌ3-2៖ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ បានកន្លងផុត។

លក្ខខណ្ឌ4៖ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៧ បានបង្ហាញឆន្ទៈថា រំលាយកិច្ចសន្យានៃរឿងក្តីនេះ។

# 2 ការធ្វើបណ្ដឹង(សំណុំរឿង1)

នៅពេលដាក់ពាក្យបណ្ដឹង  សូមដាក់ឯកសារភស្តុតាងដែលមានទៅជាមួយផង!

ភស្តុតាង = គឺជារបស់ដើម្បីបញ្ជាក់អំពីលក្ខខណ្ឌនៅក្នុងមូលហេតុនៃការទាមទារ

# 2 ការធ្វើបណ្តឹង(សំណុំរឿង1)

ឧទាហរណ៍អំពីភស្តុតាងជាឯកសារ

លក្ខខណ្ឌ1 : កិច្ចសន្យាលក់ទិញ ⟵ លិខិតកិច្ចសន្យាលក់ទិញ

លក្ខខណ្ឌ2 : ការប្រគល់ដី និង ផ្ទះ(L) ⟵ សៀវភៅគោលបញ្ជី(ការចុះបញ្ជីផ្ទេរកម្មសិទ្ធិពី X ទៅ Y )

លក្ខខណ្ឌ3–1 : ការដាស់តឿន ⟵ លិខិតដាស់តឿន

# 2 ការធ្វើបណ្តឹង(សំណុំរឿង1)

លក្ខខណ្ឌ3–2:ការកន្លងផុតអំឡុងពេលដាស់តឿន ⟵ មិនត្រូវការភស្តុតាង

(ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១២៣ កថា.ទី២)
អង្គហេតុដែលភាគីបានសារភាពនៅចំពោះមុខតុលាការ និង អង្គហេតុដែលតុលាការយល់ឃើញថាមានភាពជាក់ស្តែង តុលាការពុំចាំបាច់ទទួលស្គាល់អង្គហេតុនោះដោយផ្អែកលើភស្តុតាងទេ។

លក្ខខណ្ឌ4:ការបង្ហាញឆន្ទៈរំលាយ ⟵ លិខិតជូនដំណឹងអំពីការរំលាយ

# 2 ការធ្វើបណ្ដឹង (សំណុំរឿង1)

ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្ដឹង




មូលហេតុនៃការទាមទារ = "អង្គហេតុដែលជាមូលហេតុនៃការទាមទារ" (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៧៥ កថា.ទី៣))

"អង្គហេតុដែលចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ" (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៧៥ (កថា.ទី២) ចំណុច ខ.)

"ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ"(ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៧៥ កថា.ទី២ ចំណុច ខ.)

# 2 ការធ្វើបណ្តឹង(សំណុំរឿង1)

## ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង

(ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៧៥)

២-នៅក្នុងលិខិតនៃពាក្យបណ្តឹង ត្រូវសរសេរបញ្ជាក់នូវចំណុចខាងក្រោម៖

ក-ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។

ខ-ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ និង អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ ។

៣-នៅក្នុងពាក្យបណ្តឹង ក្រៅពីចំណុចដែលបានកំណត់នៅក្នុងចំណុច ខ នៃកថាខណ្ឌទី២ ខាងលើនេះ ដើមចោទគប្បីសរសេរបញ្ជាក់ឲ្យបានច្បាស់លាស់នូវអង្គហេតុដែលជាមូលហេតុនៃការទាមទារ និង តាមចំណុចដែលត្រូវការបញ្ជាក់ភស្តុតាង គប្បីសរសេរបញ្ជាក់នូវអង្គហេតុសំខាន់ៗ ក្នុងចំណោមអង្គហេតុទាំងមូលដែលទាក់ទងនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ និង ភស្តុតាង។

# 2 ការធ្វើបណ្តឹង(សំណុំរឿង1)

ពាក្យបណ្តឹងបានធ្វើរួចរាល់

យោងគម្រូពាក្យបណ្តឹង(សំណុំរឿង 1)

បង់ប្រាក់ប្រដាប់ក្តីតុលាការ (ក្រមនីតិវិធីរដ្ឋប្បវេណី ចាប់ពីមាត្រា៥៩) និងដាក់ពាក្យបណ្តឹងនៅតុលាការដែលមានសមត្ថកិច្ច(ក្រមនីតិវិធីរដ្ឋប្បវេណី ចាប់ពីមាត្រា៧)

# 3 ការបន្តចូលកាលបរិច្ឆេទ(សំណុំរឿង1)

ការចាប់ផ្ដើមនៃការសម្រេចសេចក្ដី



ការបញ្ជូនពាក្យបណ្ដឹង (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៧៩)

ការដាក់ពាក្យបណ្ដឹង
(ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៧៥ កថា.ទី១)

ការកំណត់កាលបរិច្ឆេទត្រៀមសម្រាប់ការទាញហេតុផល
(ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៨០ កថា.ទី១)





# 3 ការបន្តចូលកាលបរិច្ឆេទ(សំណុំរឿង1)

ឯកសារចម្លើយ ＝ ការអះអាងរបស់ចុងចម្លើយចំពោះពាក្យបណ្តឹង

នៅប្រទេសជប៉ុន ចុងចម្លើយដាក់ឯកសារចម្លើយទៅកាន់តុលាការ និង ដើមចោទ ក្នុងរយៈពេលប្រហែលជា១សប្តាហ៍នៅមុនកាលបរិច្ឆេទលើកទី១ ។

ឯកសារចម្លើយនឹងមានសុពលភាពជាមធ្យោបាយក្នុងការបញ្ជាក់ឲ្យច្បាស់អំពីចំណុចវិវាទ។



# 3 ការបន្តចូលកាលបរិច្ឆេទ(សំណុំរឿង1)

នៅក្នុងឯកសារចម្លើយត្រូវសរសេរអំពី៖

- ការឆ្លើយតបចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារនៅក្នុងពាក្យបណ្ដឹង
- ការទទួលស្គាល់ ឬ មិនទទួលស្គាល់នូវអង្គហេតុដែលដើមចោទបានសរសេរនៅក្នុងពាក្យបណ្ដឹង
- អង្គហេតុតវ៉ាជាអាទិ៍។

(ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១០១ កថា.ទី៣)

៣-នៅក្នុងឯកសារត្រៀមដែលចុងចម្លើយដាក់ទៅតុលាការលើកដំបូង ត្រូវមានសរសេរអំពីការឆ្លើយតប ចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារនៅក្នុងពាក្យបណ្ដឹង និង ការទទួលស្គាល់ ឬ មិនទទួលស្គាល់នូវអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្ដឹង និង អង្គហេតុតវ៉ាចំពោះអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្ដឹង ជាអាទិ៍។

# 3 ការបន្តចូលកាលបរិច្ឆេទ(សំណុំរឿង1)

ការឆ្លើយតបចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារនៅក្នុងពាក្យបណ្តឹង

ជាទូទៅ ចុងចម្លើយច្បាស់ជាទាមទារនូវ៖

- ការច្រានចោលការទាមទាររបស់ដើមចោទ
  ( ឬ ការលើកចោលពាក្យបណ្តឹង)
- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

# 3 ការបន្តចូលកាលបរិច្ឆេទ(សំណុំរឿង1)

ការទទួលស្គាល់ ឬ មិនទទួលស្គាល់នូវអង្គហេតុដែលដើមចោទបានសរសេរនៅក្នុងពាក្យបណ្តឹង




សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត

ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ

មូលហេតុនៃការទាមទារ ៖ ចុងចម្លើយសរសេរអំពីការទទួលស្គាល់ ឬ មិនទទួលស្គាល់ចំពោះមូលហេតុនៃការទាមទារ!

តើការទទួលស្គាល់ ឬ មិនទទួលស្គាល់ជាអ្វី?

# 3 ការបន្តចូលកាលបរិច្ឆេទ(សំណុំរឿង1)

ការទទួលស្គាល់ ឬ មិនទទួលស្គាល់

① ទទួលស្គាល់ (ការសារភាព)

② ភាពស្ងៀមស្ងាត់

ក្រៅពីករណីដែលតុលាការគិតពិចារណាអំពីដំណើរការ និង ខ្លឹមសារនៃរឿងក្តី ហើយយល់ឃើញថាភាគីនោះបានតវ៉ាអំពីអង្គហេតុ ភាគីនោះត្រូវបានចាត់ទុកថាបានសារភាពអំពីអង្គហេតុនោះ។ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៩៦ កថា.ទី១)

③ មិនដឹង

ត្រូវបានសន្មតថាបានតវ៉ាអំពីអង្គហេតុ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៩៦ កថា.ទី២)

④ មិនទទួលស្គាល់

# 3 ការបន្តចូលកាលបរិច្ឆេទ(សំណុំរឿង1)

ការទទួលស្គាល់ ឬ មិនទទួលស្គាល់នូវអង្គហេតុដែលដើមចោទបានសរសេរនៅក្នុងពាក្យបណ្តឹង



ផ្នែកដែល Y លើកឡើង

នៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៧ ខ្ញុំបានសន្យាជាមួយនឹង X ថានឹងទិញដី និង ផ្ទះ (L) ក្នុងតម្លៃ១០ម៉ឺនដុល្លារ ហើយបានបង់ប្រាក់កក់ចំនួន៣ម៉ឺនដុល្លារ។ ក្រោយមក X បានប្រគល់ដី និង ផ្ទះ (L) ឲ្យមកខ្ញុំ ហើយក៏បានផ្ទេរឈ្មោះដែលបានចុះបញ្ជីនោះឲ្យមកខ្ញុំផងដែរ។

ដោយសារតែខ្ញុំរៀងខ្វះប្រាក់បន្តិច ក៏បានសុំឲ្យ X រង់ចាំការបង់ប្រាក់ចំនួន៧ម៉ឺនទៀត។ ក្រោយមក នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៧ ខ្ញុំបានប្រគល់ប្រាក់ដែលនៅខ្វះចំនួន៧ម៉ឺនដុល្លារ ឲ្យទៅបុប្ផាដែលជាប្រពន្ធរបស់ X ។

ចំពោះលិខិតដាស់តឿន ឬ លិខិតជូនដំណឹងអំពីការរំលាយវិញ ខ្ញុំមិនបានទទួលឡើយ។

# 3 ការបន្តចូលកាលបរិច្ឆេទ (សំណុំរឿង1)

ការទទួលស្គាល់ ឬ មិនទទួលស្គាល់នូវអង្គហេតុដែលដើមចោទបានសរសេរនៅក្នុងពាក្យបណ្តឹង



- លក្ខខណ្ឌ1: ការបង្កើតកិច្ចសន្យាលក់ទិញ → ទទួលស្គាល់
- លក្ខខណ្ឌ2: ការប្រគល់ដី និង ផ្ទះ(L) និង ការផ្ទេរនូវការចុះបញ្ជី → ទទួលស្គាល់
- លក្ខខណ្ឌ3: ការដាស់តឿន → មិនដឹង
- លក្ខខណ្ឌ4: ការបង្ហាញឆន្ទៈអំពីការរំលាយ → មិនដឹង

ផ្នែកដែល Y លើកឡើង

# 3 ការបន្តចូលកាលបរិច្ឆេទ(សំណុំរឿង1)

អង្គហេតុតវ៉ាចំពោះអង្គហេតុដែលដើមចោទបានសរសេរនៅក្នុងពាក្យបណ្ដឹង ជាអាទិ៍

ការតវ៉ា = អង្គហេតុដែលស្របទៅនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ ហើយសុពលភាពគតិយុត្តនៃការទាមទាររបស់អង្គហេតុនោះ ធ្វើឲ្យរារាំងនូវសុពលភាពគតិយុត្តដែលកើតចេញពីមូលហេតុនៃការទាមទារ។



ផ្នែកដែល Y លើកឡើង

ក្រោយមក នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៧ ខ្ញុំបានប្រគល់ប្រាក់ដែលនៅខ្វះចំនួន៧ម៉ឺនដុល្លារ ឲ្យទៅបុប្ផាដែលជាប្រពន្ធរបស់ X ។

↓

ការតវ៉ាអំពីការសង

# 3 ការបន្តចូលកាលបរិច្ឆេទ(សំណុំរឿង1)

ការបញ្ជាក់ឲ្យច្បាស់អំពីចំណុចវិវាទ



ពាក្យបណ្តឹង



ឯកសារចម្លើយ



លក្ខខណ្ឌ1:ការបង្កើតកិច្ចសន្យាលក់ទិញ ○
លក្ខខណ្ឌ2:ការប្រគល់ដី និង ផ្ទះ(L) និងការផ្ទេរនូវការចុះបញ្ជី ○
លក្ខខណ្ឌ3:ការដាស់តឿន △
លក្ខខណ្ឌ4:ការបង្ហាញឆន្ទៈអំពីការរំលាយ △
ការតវ៉ា:ការសង

ចំណុចវិវាទគឺ

- អត្ថិភាព ឬ នត្ថិភាពនៃការដាស់តឿន?
- អត្ថិភាព ឬ នត្ថិភាពនៃការបង្ហាញឆន្ទៈអំពីការរំលាយ?
- អត្ថិភាព ឬ នត្ថិភាពនៃការសង?

# 3 ការបន្តចូលការបរិច្ឆេទ(សំណុំរឿង1)

ការបន្ថែមនូវការបញ្ជាក់ភស្តុតាងចំពោះការអះអាងរបស់ដើមចោទ និង ចុងចម្លើយ



# 4 សាលក្រម(សំណុំរឿង1)

ឧទាហរណ៍ក្នុងករណីដែលដើមចោទបានឈ្នះក្តី



សេចក្តីសម្រេចបញ្ចប់

1. បង្គាប់ឲ្យចុងចម្លើយ Y ប្រគល់ដី និង ផ្ទះ(L) ឲ្យដើមចោទ X ដោយទទួលបានប្រាក់ដែលបានបង់ចំនួន៣ម៉ឺនដុល្លារពីដើមចោទ X មកវិញ
2. បង្គាប់ឲ្យចុងចម្លើយ Y ធ្វើនីតិវិធីចុះបញ្ជីអំពីការលុបការចុះបញ្ជីការផ្ទេរកម្មសិទ្ធិដែលបានចុះបញ្ជីលេខ ○○ ដោយទទួលការបង់ប្រាក់ចំនួន៣ម៉ឺនដុល្លារពីដើមចោទ X មកវិញ ដោយមូលហេតុរំលាយកិច្ចសន្យាចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៧។
3. ច្រានចោលការទាមទារក្រៅពីនេះរបស់ដើមចោទ X
4. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ Y
5. សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នបានតែចំណុចទី១ ប៉ុណ្ណោះ។

# 4 សាលក្រម (សំណុំរឿង1)

ឧទាហរណ៍ក្នុងករណីដែលដើមចោទបានចាញ់ក្តី

(ឧទាហរណ៍ថាតុលាការបានទទួលស្គាល់នូវការតវ៉ាអំពីការសងដែល Y អះអាង)



សេចក្តីសម្រេចបញ្ចប់

1. ច្រានចោលការទាមទារគ្រប់ចំណុចរបស់ដើមចោទ X ។
2. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទX។

# ទី2 សំណុំរឿង2

ភតិបតី X និងភតិកៈ Y ហើយកម្មវត្ថុនៃភតិសន្យា គឺ ដី និង ផ្ទះ(L) ថ្លៃឈ្នួលក្នុងមួយខែ ២០០០ដុល្លារ និង រយៈពេលនៃភតិសន្យា គឺរយៈពេល២៤ខែ។ ចំពោះវិធីនៃការបង់ប្រាក់ឈ្នួលមានសរសេរនៅក្នុងកិច្ចសន្យានោះ ពោលគឺ ភតិកៈត្រូវបង់ប្រាក់កក់ (Deposit) ចំនួន៤០០០ដុល្លារនៅថ្ងៃចុះកិច្ចសន្យា ដើម្បីធានាឲ្យបាននូវការអនុវត្តតាមខ្លឹមសារនៃកិច្ចសន្យា។ ហើយភតិកៈត្រូវបង់ថ្លៃឈ្នួលជារៀងរាល់ខែ នៅថ្ងៃទី១ ម្យ៉ាងវិញទៀត ក្នុងករណីដែលមិនបានបង់ថ្លៃឈ្នួលចំនួន២ខែ នឹងត្រូវចាត់ទុកថា ភតិកៈឈប់ជួល ហើយកិច្ចសន្យានឹងត្រូវរំលាយដោយស្វ័យប្រវត្តិ។ Y បានបង់ថ្លៃឈ្នួលចំនួន៦ខែ ប៉ុន្តែ ថ្លៃឈ្នួល៣ខែបន្តបន្ទាប់មកទៀតមិនបានបង់ឡើយ។ ទោះបីជា X បានដាស់តឿន Y ឲ្យបង់ថ្លៃឈ្នួលក៏ដោយ ក៏មិនមានការឆ្លើយតបពី X ដែរ។ បច្ចុប្បន្ននេះ Y កំពុងតែរស់នៅលើដី និង ផ្ទះ(L) នោះ ។ ប៉ុន្តែ Y មិនព្រមបង់ថ្លៃឈ្នួលឲ្យមក X ឡើយ។

<u>ប្រសិនបើ X ចង់យកដី និង ផ្ទះ(L) មកវិញ តើត្រូវធ្វើដូចម្តេច?</u>

→ X បានមកជួបមេធាវី ហើយពិភាក្សា។

# ទី2 សំណុំរឿង2

<រូបភាព>



# 1 ការទទួលរឿងក្តី (សំណុំរឿង2)

ប្រសិនបើអ្នកបានទទួលរឿងក្តីដូចករណីនេះ!  តើនឹងធ្វើយ៉ាងដូចម្តេច?



# 1 ការទទួលរឿងក្តី (សំណុំរឿង2)

ជាដំបូង សូមបញ្ជាក់អំពីគោលបំណងរបស់អតិថិជន !

គោលបំណងរបស់អតិថិជនគឺ

ចង់បានដី និង ផ្ទះ (L) មកវិញ!



# 1 ការទទួលរឿងក្តី (សំណុំរឿង2)

តើចាំបាច់ត្រូវបង្ហាញឆន្ទៈអំពីការរំលាយដែរ ឬទេ?



ក្នុងករណីដែលមិនបានបង់ថ្លៃឈ្នួលចំនួន២ខែ កិច្ចសន្យា
នៃរឿងក្តីនេះនឹងត្រូវរំលាយដោយស្វ័យប្រវត្តិ។



លិខិតភតិសន្យា

ថ្ងៃទី១ ខែកញ្ញា មិនបានបង់ថ្លៃឈ្នួល

ថ្ងៃទី១ ខែតុលា មិនបានបង់ថ្លៃឈ្នួល



ថ្ងៃទី១ ខែតុលា អានុភាពនៃការរំលាយបានកើតឡើង!

# 2 ការធ្វើពាក្យបណ្ដឹង(សំណុំរឿង2)

ជាដំបូង សូមគិតអំពីខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ !

គោលបំណងរបស់អតិថិជនគឺ

ចង់បានដី និង ផ្ទះ(L)ត្រឡប់មកវិញ !



ចង់ឲ្យសងការកាន់កាប់ដី និង ផ្ទះ (L)ត្រឡប់មកវិញ !

# 2 ការធ្វើពាក្យបណ្ដឹង (សំណុំរឿង2)

សាកគិតឲ្យបានលម្អិតអំពីខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ (រូបភាព)

① ចង់ឲ្យសងការកាន់កាប់ដី និង ផ្ទះ (L) ត្រឡប់មកវិញ



# 2 ការធ្វើពាក្យបណ្តឹង(សំណុំរឿង2)

សាកគិតឲ្យបានលម្អិតអំពីខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ (រូបភាព)

② ក្រៅពីនេះ តើនៅមានអ្វីត្រូវទាមទារទៀតដែរឬទេ?






# 2 ការធ្វើពាក្យបណ្ដឹង(សំណុំរឿង2)

③ អំពីចំនួនប្រាក់ដែលត្រូវបង់សម្រាប់ថ្លៃឈ្នួលក្រោយការរំលោយ




ថ្ងៃទី១ ខែកញ្ញា មិនបានបង់ ថ្ងៃទី១ ខែតុលា មិនបានបង់

ថ្ងៃទី១ ខែតុលា ៖ អានុភាពនៃការរំលោយបានកើតឡើង

ថ្ងៃទី២ ខែតុលា~ Y កាន់កាប់ដី និង ផ្ទះ(L)ដោយខុសច្បាប់

ថ្ងៃទី២ ខែតុលា~ X→Y អាចទាមទារសំណងនៃការខូចខាត

# 2 ការធ្វើពាក្យបណ្តឹង(សំណុំរឿង2)

សាកសរសេរអំពីខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យបានលម្អិត!

① អំពីការសងការកាន់កាប់ដី និង ផ្ទះ(L)ត្រឡប់មកវិញ
"បង្គាប់ឲ្យចុងចម្លើយ Y ចុះចេញពីដី និង ផ្ទះ(L) ហើយប្រគល់ឲ្យទៅដើមចោទ X"

② អំពីថ្លៃឈ្នួលដែលមិនទាន់បានបង់ (សរុប ២០០០ដុល្លារ ៖ ថ្លៃឈ្នួលខែកញ្ញាចំនួន ២០០០ដុល្លារ)
"បង្គាប់ឲ្យចុងចម្លើយ Y បង់ប្រាក់ចំនួន ២០០០ដុល្លារ និង បង់ការប្រាក់នៃខែនេះ ចំនួន៥%ក្នុង១ឆ្នាំ គិតចាប់ពីថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៧ រហូតដល់ថ្ងៃសងរួច"

③ អំពីសំណងការខូចខាតក្រោយពីរំលាយកិច្ចសន្យាដែលស្មើនឹងថ្លៃឈ្នួល
"បង្គាប់ឲ្យចុងចម្លើយ Y បង់ប្រាក់ចំនួន២០០០ដុល្លារក្នុង១ខែឲ្យទៅដើមចោទ X គិតចាប់ពីថ្ងៃទី២ ខែតុលា ឆ្នាំ២០១៧ រហូតដល់ពេលដែលចុងចម្លើយបានចុះចេញ ហើយប្រគល់ពីដី និង ផ្ទះ(L)"

# 2 ការធ្វើពាក្យបណ្ដឹង (សំណុំរឿង2)

① ការចុះចេញ ហើយប្រគល់ដី និង ផ្ទះ(L)




តើដើមចោទត្រូវអះអាងអំពីអង្គហេតុបែបណា?

សិទ្ធិទាមទារឲ្យធ្វើបដិទានឡើងវិញដោយផ្អែកលើការរំលោយកិច្ចសន្យា (ក្រមរដ្ឋប្បវេណី មាត្រា៤១១ កថា.ទី២)

ការចុះចេញ ហើយប្រគល់ដី និង ផ្ទះ(L)

សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត

ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ

# 2 ការធ្វើពាក្យបណ្ដឹង (សំណុំរឿង2)

② ថ្លៃឈ្នួលដែលមិនទាន់បានបង់




សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត

ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ

តើដើមចោទត្រូវអះអាងអំពីអង្គហេតុបែបណា?

សិទ្ធិទាមទារឲ្យបង់ថ្លៃឈ្នួលផ្អែកលើភតិសន្យា (ក្រមរដ្ឋប្បវេណី មាត្រា៥៨៧)

ការបង់ថ្លៃឈ្នួលដែលមិនទាន់បានបង់

# 2 ការធ្វើពាក្យបណ្ដឹង(សំណុំរឿង2)

## ③ ការសងសំណងនៃការខូចខាតដែលស្មើនឹងថ្លៃឈ្នួល




សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត

ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ

តើដើមចោទត្រូវអះអាងអំពីអង្គហេតុបែបណា?

សិទ្ធិទាមទារសំណងនៃការខូចខាតផ្អែកលើការយឺតយ៉ាវក្នុងការអនុវត្តចំពោះកាតព្វកិច្ចសងកម្មវត្ថុនៃកិច្ចសន្យា (ក្រមរដ្ឋប្បវេណី មាត្រា៣៩៨)

ការសងសំណងនៃការខូចខាត
ដែលស្មើនឹងថ្លៃឈ្នួល

# 2 ការធ្វើពាក្យបណ្ដឹង(សំណុំរឿង2)

① មូលហេតុនៃការទាមទាររបស់សិទ្ធិទាមទារឲ្យធ្វើបដិទានឡើងវិញដោយផ្អែកលើការរំលាយ

លក្ខខណ្ឌ1:ការបង្កើតកិច្ចសន្យាដើម (ក្រមរដ្ឋប្បវេណី មាត្រា៤០៧ ជាដើម)

លក្ខខណ្ឌ2:ការផ្ដល់តាវកាលិក (ប្រាក់) ជាអាទិ៍ ផ្អែកលើកិច្ចសន្យា (លក្ខខណ្ឌ1) (ក្រមរដ្ឋប្បវេណី មាត្រា៤១១ កថា.ទី២)

លក្ខខណ្ឌ3:អង្គហេតុដែលជាមូលហេតុនៃការកើតឡើងសិទ្ធិរំលាយ = អត្ថិភាពនៃខសន្យាពិសេសក្នុងកិច្ចសន្យានេះ ហើយមានស្ថានភាពដែលត្រូវទៅនឹងខសន្យាពិសេសនោះ

លក្ខខណ្ឌ4:(ក្រមរដ្ឋប្បវេណី មាត្រា៤០៩ កថា.ទី១) ការបង្ហាញឆន្ទៈថារំលាយកិច្ចសន្យានៃ(លក្ខខណ្ឌ1)→ មិនទាមទារ

※ ដោយមូលហេតុថា ផ្អែកតាមខសន្យាពិសេសនៃកិច្ចសន្យា ទោះបីជាភតិបតីមិនបានបង្ហាញឆន្ទៈអំពីការរំលាយក៏ដោយ ប្រសិនបើភតិកៈមិនបានបង់ថ្លៃឈ្នួលចំនួន២ខែ កិច្ចសន្យានឹងត្រូវរំលាយភ្លាមៗ។

# 2 ការធ្វើពាក្យបណ្ដឹង(សំណុំរឿង2)

② មូលហេតុនៃការទាមទាររបស់សិទ្ធិទាមទារឲ្យបង់ថ្លៃឈ្នួលដែលមិនទាន់បានបង់

↓

លក្ខខណ្ឌ1 : ការបង្កើតភតិសន្យា (ក្រមរដ្ឋប្បវេណី មាត្រា៥៩៧)

លក្ខខណ្ឌ2 : ការប្រគល់កម្មវត្ថុផ្អែកលើកិច្ចសន្យា (លក្ខខណ្ឌ1) (ក្រមរដ្ឋប្បវេណី មាត្រា៥៩៦ និង មាត្រា ៣៨៦)

លក្ខខណ្ឌ3 : ការមកដល់នៃកាលបរិច្ឆេទបង់ថ្លៃឈ្នួល

# 2 ការធ្វើពាក្យបណ្តឹង(សំណុំរឿង2)

③ មូលហេតុនៃការទាមទាររបស់សិទ្ធិទាមទារឲ្យសងសំណងនៃការខូចខាតដែលស្មើនឹងថ្លៃឈ្នួល

លក្ខខណ្ឌ1:ការបង្កើតកិច្ចសន្យាដើម (ក្រមរដ្ឋប្បវេណី មាត្រា៤០៧ ជាដើម)

លក្ខខណ្ឌ2:ការផ្តល់តាវកាលិកនូវប្រាក់ជាដើមផ្អែកលើកិច្ចសន្យា (លក្ខខណ្ឌ1) (ក្រមរដ្ឋប្បវេណី មាត្រា៤១១ កថា.ទី២)

លក្ខខណ្ឌ3:អង្គហេតុដែលជាមូលហេតុនៃការកើតឡើងសិទ្ធិរំលាយ = អត្ថិភាពនៃខសន្យាពិសេសក្នុងកិច្ចសន្យានេះ ហើយមានស្ថានភាពដែលត្រូវទៅនឹងខសន្យាពិសេសនោះ

លក្ខខណ្ឌ4:(ក្រមរដ្ឋប្បវេណី មាត្រា៤០៩ កថា.ទី១) ការបង្ហាញឆន្ទៈថារំលាយកិច្ចសន្យានៃ(លក្ខខណ្ឌ1)→ មិនចាំបាច់

លក្ខខណ្ឌ5: ការកើតឡើងនូវការខូចខាត និង ចំនួននៃការខូចខាត

# 2 ការធ្វើពាក្យបណ្ដឹង(សំណុំរឿង2)



# 2 ការធ្វើពាក្យបណ្តឹង(សំណុំរឿង2)

មូលហេតុនៃការទាមទារក្នុងរឿងក្តីនេះ

លក្ខខណ្ឌ1:នៅថ្ងៃទី១ ខែមីនា ឆ្នាំ២០១៧ ភតិបតី X បានជួលដី និង ផ្ទះ (L) ក្នុងតម្លៃថ្លៃឈ្នួល ២០០០ដុល្លារក្នុង១ខែ ឲ្យទៅភតិកៈ Y ។

លក្ខខណ្ឌ2:នៅថ្ងៃទី១ ខែមីនា ឆ្នាំ២០១៧ X បានប្រគល់ដី និង ផ្ទះ(L) ឲ្យទៅ Y។

លក្ខខណ្ឌ3–1:ភតិសន្យានៃរឿងក្តីនេះ មានខសន្យាពិសេសថែងថា "ប្រសិនបើភតិកៈមិនបានបង់ថ្លៃឈ្នួលចំនួនពេល២ខែ កិច្ចសន្យានេះនឹងត្រូវរំលាយភ្លាមៗ។" " ថ្លៃឈ្នួលប្រចាំខែ ត្រូវបង់នៅថ្ងៃទី១នៃខែនោះ"។

# 2 ការធ្វើពាក្យបណ្តឹង(សំណុំរឿង2)

លក្ខខណ្ឌ3-2:ថ្ងៃទី១ ខែកញ្ញា និង ថ្ងៃទី១ ខែតុលា ឆ្នាំ២០១៧ បានកន្លងផុតទាំងអស់។

លក្ខខណ្ឌ4:មិនចាំបាច់អះអាង

លក្ខខណ្ឌ5:ចំនួនប្រាក់ដែលស្មើនឹងថ្លៃឈ្នួលរបស់ដី និង ផ្ទះ(L) គិតចាប់ពីថ្ងៃទី២ ខែតុលា ឆ្នាំ២០១៧មក គឺ ២000ដុល្លារ/ខែ។

# 2 ការធ្វើពាក្យបណ្តឹង(សំណុំរឿង2)

ឧទាហរណ៍នៃភស្តុតាងជាឯកសារ

លក្ខខណ្ឌ1:ភតិសន្យា ⟵ លិខិតភតិសន្យា

លក្ខខណ្ឌ2:ការប្រគល់ដី និង ផ្ទះ(L)

លក្ខខណ្ឌ3–1:អត្ថិភាពនៃខសន្យាពិសេស ⟵ លិខិតភតិសន្យា

# 2 ការធ្វើពាក្យបណ្តឹង(សំណុំរឿង2)

លក្ខខណ្ឌ3-2:ការមកដល់នៃកាលបរិច្ឆេទបង់ថ្លៃឈ្នួល ⟵ មិនចាំបាច់ភស្តុតាង

លក្ខខណ្ឌ4: ការបង្ហាញឆន្ទៈអំពីការរំលាយ (មិនចាំបាច់អះអាង និង បញ្ជាក់ភស្តុតាង)

លក្ខខណ្ឌ5: ការកើតឡើងនូវការខូចខាត និង ចំនួននៃការខូចខាត ⟵ លិខិតភតិសន្យា

# 3 ការបន្តចូលកាលបរិច្ឆេទ(សំណុំរឿង2)

## ផ្នែកដែល Y លើកឡើង



នៅថ្ងៃទី១ ខែមីនា ឆ្នាំ២០១៧ ខ្ញុំបានជួលដី និងផ្ទះ (L) ពី X។ នៅថ្ងៃនោះ X បានប្រគល់ដី និង ផ្ទះ (L)មកឲ្យខ្ញុំ។ ប៉ុន្តែ ផ្ទះនោះជ្រាបទឹកខ្លាំងពេក ហើយនៅរដូវភ្លៀងមិនអាចស្នាក់នៅជាប្រចាំបានឡើយ។ ដូច្នេះ ចាប់តាំងពីថ្ងៃទី១ ខែសីហា ឆ្នាំ២០១៧មក ខ្ញុំបានទាមទារឲ្យ X ធ្វើការជួសជុល។ ប៉ុន្តែ ដោយហេតុថា X មិនបានជួសជុលអ្វីបន្តិចសោះឡើយ ហេតុនេះហើយ ទើបខ្ញុំបានឈប់បង់ថ្លៃឈ្នួលចាប់តាំងពីខែកញ្ញា ឆ្នាំ២០១៧ រហូតមក។ ខ្ញុំមិនចាំបាច់ត្រូវបង់ថ្លៃឈ្នួលសម្រាប់ផ្ទះដែលមិនអាចស្នាក់នៅបានឡើយ។ ដូច្នេះហើយ ភ្លាមៗនោះ X ក៏បានចាប់ផ្តើមនិយាយមកកាន់ខ្ញុំថា រំលាយកិច្ចសន្យានេះ។

# 3 ការបន្តចូលកាលបរិច្ឆេទ(សំណុំរឿង2)

ផ្នែកដែល Y បានលើកឡើង
(ទទួលស្គាល់ ឬ មិនទទួលស្គាល់)



លក្ខខណ្ឌ1:ការបង្កើតភតិសន្យា → ទទួលស្គាល់

លក្ខខណ្ឌ2:ការប្រគល់ដី និង ផ្ទះ (L) → ទទួលស្គាល់

លក្ខខណ្ឌ3−1:អត្ថិភាពនៃខសន្យាពិសេស → ទទួលស្គាល់

លក្ខខណ្ឌ3−2:ការកន្លងផុតនៃកាលបរិច្ឆេទបង់ថ្លៃឈ្នួល (ចំនួន២ខែ) → ទទួលស្គាល់

លក្ខខណ្ឌ4:ការបង្ហាញឆន្ទៈអំពីការរំលាយ → មិនចាំបាច់ ទទួលស្គាល់ ឬមិនទទួលស្គាល់ទេ

លក្ខខណ្ឌ5: ការកើតឡើងនូវការខូចខាត និង ចំនួននៃការខូចខាត → មិនដឹង

# 3 ការបន្តចូលកាលបរិច្ឆេទ(សំណុំរឿង2)

ការលើកឡើងរបស់Y(ការតវ៉ា)



ប៉ុន្តែ ផ្ទះនោះជ្រាបទឹកខ្លាំងពេក ហើយនៅរដូវភ្លៀងមិនអាចស្នាក់នៅជាប្រចាំបានឡើយ។ ដូច្នេះ ចាប់តាំងពីថ្ងៃទី១ ខែសីហា ឆ្នាំ២០១៧មក ខ្ញុំបានទាមទារឲ្យ X ធ្វើការជួសជុល។ ប៉ុន្តែ ដោយហេតុថា Xមិនបានជួសជុលអ្វីបន្តិចសោះឡើយ។ ខ្ញុំមិនចាំបាច់ត្រូវបង់ថ្លៃឈ្នួលសម្រាប់ផ្ទះដែលមិនអាចស្នាក់នៅបានឡើយ។

↓

ការតវ៉ាអំពីការមិនអនុវត្តករណីយកិច្ចជួសជុលរបស់ភតិបតី

# 3 ការបន្តចូលកាលបរិច្ឆេទ(សំណុំរឿង2)

ការបញ្ជាក់ឲ្យច្បាស់
អំពីចំណុចវិវាទ



ពាក្យបណ្ដឹង



ឯកសារចម្លើយ



លក្ខខណ្ឌ1:ការបង្កើតភតិសន្យា ○
លក្ខខណ្ឌ2:ការប្រគល់ដី និង ផ្ទះ(L) ○
លក្ខខណ្ឌ3:អត្ថិភាពនៃខសន្យាពិសេស និង ការកន្លងផុតនៃកាលបរិច្ឆេទបង់ថ្លៃឈ្នួល (ចំនួន២ខែ) ○
លក្ខខណ្ឌ4:ការបង្ហាញឆន្ទៈអំពីការរំលាយ △
លក្ខខណ្ឌ5: ការកើតឡើងនូវការខូចខាត និង ចំនួននៃការខូចខាត △
ការតវ៉ា:ការមិនអនុវត្តករណីយកិច្ចជួសជុលរបស់ភតិបតី

ចំណុចវិវាទគឺ

- តើមានការខូចខាតឬទេ? បើមាន ចំនួនប៉ុន្មាន?
- តើមានការជ្រាបទឹកឬទេ? បើមាន កម្រិតណា?

# 4 សាលក្រម(សំណុំរឿង2)

## ឧទាហរណ៍ក្នុងករណីដែលដើមចោទបានឈ្នះក្តី



សេចក្តីសម្រេចបញ្ជាប់

1. បង្គាប់ឲ្យចុងចម្លើយ Y ប្រគល់ដី និង ផ្ទះ(L) ឲ្យដើមចោទ X
2. បង្គាប់ឲ្យចុងចម្លើយY បង់ប្រាក់ចំនួន២០០០ដុល្លារក្នុង១ខែឲ្យទៅដើមចោទX គិតចាប់ពីថ្ងៃទី២ ខែតុលា ឆ្នាំ២០១៧ រហូតដល់ពេលដែលចុងចម្លើយបានប្រគល់ពីដី និង ផ្ទះ(L)។
3. បង្គាប់ឲ្យចុងចម្លើយ Y បង់ប្រាក់ចំនួន ២០០០ដុល្លារ និង បង់ការប្រាក់នៃខែនេះចំនួន៥%ក្នុង១ឆ្នាំ គិតចាប់ពីថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៧ រហូតដល់ថ្ងៃសងរួច។
4. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយY។
5. សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នចំណុចទី១ ដល់ ទី៣។

# 4 សាលក្រម(សំណុំរឿង2)

ឧទាហរណ៍ក្នុងករណីដែលដើមចោទបានចាញ់ក្តី (ឧទាហរណ៍ថាតុលាការបានទទួលស្គាល់នូវការតវ៉ាដែលYអះអាងអំពីការមិនអនុវត្តករណីយកិច្ចជួសជុលរបស់ភតិបតី)



សេចក្តីសម្រេចបញ្ចប់

1. ច្រានចោលការទាមទារគ្រប់ចំណុចរបស់ដើមចោទ X ។
2. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ X។

# ទី3 សំណុំរឿង3

នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៧ X បានឲ្យប្រាក់ទៅAដែលជាមិត្តសំឡាញ់ខ្ចីចំនួន១0ម៉ឺនដុល្លារ ដោយកំណត់យកថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៧ ជាកាលបរិច្ឆេទនៃការសង។ ប៉ុន្តែ ទោះបីជាកាលបរិច្ឆេទនៃការសងបានកន្លងផុតក៏ដោយ ក៏ A ដូចជាមិនចង់សងមកឲ្យ X វិញទាល់តែសោះ។ ដូច្នេះ នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៧ X បានមកការិយាល័យមេធាវី ហើយពិភាក្សាអំពីរឿងក្ដីនេះ ព្រមទាំងពឹង Y ឲ្យទទួលបន្ទុកលើរឿងក្ដីនេះ ។ នៅពេលនោះ X បានបង់ប្រាក់ជាមុនសម្រាប់សេវាមេធាវីចំនួន ១000ដុល្លារឲ្យទៅ Y ហើយបានធ្វើកិច្ចសន្យាដែលមានខ្លឹមសារថា នៅថ្ងៃក្រោយ ប្រសិនបើ A បានសងប្រាក់កម្ចីនៃរឿងក្ដីនេះឲ្យទៅ X វិញ X ត្រូវបង់១0%នៃប្រាក់នោះឲ្យទៅ Y ជាសោហ៊ុយចំពោះភាពជោគជ័យលើរឿងក្ដី។ ប៉ុន្តែក្រោយមក X បានឮពី B ដែលជាមិត្តសំឡាញ់ថា មេធាវី Y នេះ ប៉ិនប្រសប់ក្នុងការនិយាយស្ដី ក៏ប៉ុន្តែមិនធ្វើការងារឲ្យកូនក្ដីទាល់តែសោះ ដូច្នេះក៏គិតថា ចង់បញ្ចប់កិច្ចសន្យាខាងលើជាមួយមេធាវី Y ។

<u>តើ X ត្រូវធ្វើដូចម្ដេចក្នុងករណីដែលចង់ឲ្យ Y សងប្រាក់ដែលបានបង់ជាមុននោះមកវិញ?</u>

→ X បានមករកមេធាវី ហើយពិភាក្សា។

# ទី3  សំណុំរឿង3

<រូបភាព>



# 1　ការទទួលរឿងក្តី(សំណុំរឿង3)

ប្រសិនបើអ្នកបានទទួលរឿងក្តីដូចករណីនេះ!　តើនឹងធ្វើយ៉ាងដូចម្តេច?



# 2 ការធ្វើពាក្យបណ្តឹង(សំណុំរឿង3)

ជាដំបូង សូមគិតអំពីខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ !

គោលបំណងរបស់អតិថិជនគឺ



ខ្ញុំចង់យកប្រាក់ដែលបានបង់ជាមុនសម្រាប់សេវាមេធាវីចំនួន១000ដុល្លារមកវិញ!

ចង់ឲ្យសងប្រាក់ចំនួន១000ដុល្លារវិញ!

# 2 ការធ្វើពាក្យបណ្តឹង(សំណុំរឿង3)

សាកល្បងគិតអំពីខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យបានលម្អិត (រូបភាព)

១០០០ដុល្លារ

ចង់ឲ្យសងប្រាក់ចំនួន១០០០ដុល្លារវិញ



# 2 ការធ្វើពាក្យបណ្ដឹង (សំណុំរឿង3)

សាកល្បងសរសេរអំពីខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យបានលម្អិត!

"បង្គាប់ឲ្យចុងចម្លើយY បង់ប្រាក់១000ដុល្លារ និងបង់ការប្រាក់នេះ ៥%ក្នុង១ឆ្នាំ ដោយគិតចាប់ពីថ្ងៃបន្ទាប់នៃថ្ងៃដែលបានបញ្ជូនពាក្យបណ្ដឹងរហូតដល់ថ្ងៃសងរួច។"

# 2 ការធ្វើពាក្យបណ្តឹង(សំណុំរឿង3)




សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត

ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ

តើដើមចោទត្រូវអះអាងអំពីអង្គហេតុបែបណា?

សិទ្ធិទាមទារឲ្យធ្វើបដិទានឡើងវិញដោយផ្អែកលើការ
រំលោយកិច្ចសន្យា (ក្រមរដ្ឋប្បវេណី មាត្រា៤១១ កថា.ទី២)

ការសងប្រាក់ចំនួន១០០០ដុល្លារ

# 2 ការធ្វើពាក្យបណ្ដឹង(សំណុំរឿង3)

មូលហេតុនៃការទាមទាររបស់សិទ្ធិទាមទារឲ្យធ្វើបដិទានឡើងវិញដោយផ្អែកលើការរំលាយ

លក្ខខណ្ឌ1: ការបង្កើតកិច្ចសន្យាដើម (ក្រមរដ្ឋប្បវេណី មាត្រា៤០៧ ជាដើម)

លក្ខខណ្ឌ2: ការផ្ដល់តាវកាលិកនូវប្រាក់ជាដើម ដោយផ្អែកលើកិច្ចសន្យា (លក្ខខណ្ឌ1) (ក្រមរដ្ឋប្បវេណី មាត្រា៤១១ កថា.ទី២)

លក្ខខណ្ឌ3: អង្គហេតុដែលជាមូលហេតុនៃការកើតឡើងសិទ្ធិរំលាយ (ក្រមរដ្ឋប្បវេណី មាត្រា៦៤៧ កថា.ទី១) → មិនចាំបាច់
(ក្រមរដ្ឋប្បវេណី មាត្រា ៦៤៧ កថា.ទី១)
ភាគីនីមួយៗ អាចរំលាយកិច្ចសន្យាអាណត្តិ នៅពេលណាក៏បាន។

លក្ខខណ្ឌ4: ការបង្ហាញឆន្ទៈថារំលាយកិច្ចសន្យានៃ(លក្ខខណ្ឌ1)(ក្រមរដ្ឋប្បវេណី មាត្រា៤០៩ កថា.ទី១)

# 2 ការធ្វើពាក្យបណ្តឹង(សំណុំរឿង3)



# 2 ការធ្វើពាក្យបណ្តឹង(សំណុំរឿង3)

មូលហេតុនៃការទាមទារក្នុងរឿងក្តីនេះ

លក្ខខណ្ឌ1: នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៧ អាណត្តិទាយក X បានចុះកិច្ចសន្យាអាណត្តិទៅលើរឿងក្តីនៃការទាមទារឲ្យសងប្រាក់កម្ចីរវាង X និង A ជាមួយនឹងអាណត្តិគាហក Y ដោយ Xនឹងបង់ប្រាក់បង់ជាមុនសម្រាប់សេវាមេធាវីចំនួន១000ដុល្លារ ហើយនឹងបង់ប្រាក់ចំនួន១0%នៃផលប្រយោជន៍ដែល X បានទទួលពីរឿងក្តីប្រាក់កម្ចីនេះជាសោហ៊ុយចំពោះភាពជោគជ័យ។

លក្ខខណ្ឌ2: នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៧ X បានបង់ប្រាក់ជាមុនសម្រាប់សេវាមេធាវីចំនួន១000 ដុល្លារ ឲ្យទៅY ផ្អែកតាមកិច្ចសន្យាអាណត្តិនៃរឿងក្តីនេះ ។

លក្ខខណ្ឌ3: មិនចាំបាច់អះអាង

លក្ខខណ្ឌ4: X បានបង្ហាញឆន្ទៈថារំលាយកិច្ចសន្យានៃរឿងក្តីនេះទៅកាន់ Y។

# 2 ការធ្វើពាក្យបណ្តឹង(សំណុំរឿង3)

ឧទាហរណ៍នៃភស្តុតាងជាឯកសារ

លក្ខខណ្ឌ1: កិច្ចសន្យាអាណត្តិ ← លិខិតកិច្ចសន្យាអាណត្តិ

លក្ខខណ្ឌ2: ការបង់ប្រាក់ជាមុនចំនួន១000ដុល្លារ ← ក្រដាសវិក្កយបត្រ

លក្ខខណ្ឌ3: មូលហេតុនៃការរំលោយ (មិនចាំបាច់អះអាង និង បញ្ជាក់ភស្តុតាងឡើយ)

លក្ខខណ្ឌ4: ការបង្ហាញឆន្ទៈអំពីការរំលោយ ← ពាក្យបណ្តឹង

# 3 ការបន្តចូលកាលបរិច្ឆេទ(សំណុំរឿង3)

ផ្នែកដែលYលើកឡើង



នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៧ ខ្ញុំបានទទួលសំណុំរឿងក្តីស្តីពីការទាមទារឲ្យសងប្រាក់កម្ចីរបស់ X ទៅកាន់ A។ នៅថ្ងៃនោះ ខ្ញុំបានទទួលប្រាក់ពីXដែលបានបង់ជាមុនចំនួន១000ដុល្លារ ហើយបានសន្យាថាប្រាក់ដែលនៅខ្វះ នឹងធ្វើជាប្រាក់សេវាចំពោះភាពជោគជ័យលើរឿងក្តីនេះ។ បន្ទាប់ពីនោះមក ខ្ញុំបានចរចាបន្ថែមជាមួយនឹងA ហើយបានទាមទារឲ្យAសងប្រាក់កម្ចីនោះ។ សោហ៊ុយសម្រាប់ចំណាយចំពោះការចរចានោះ ក៏បានកើតឡើងដែរ។ ប៉ុន្តែ ភ្លាមៗ X ក៏បានដាក់ពាក្យបណ្តឹងប្តឹងខ្ញុំ។

# 3 ការបន្តចូលកាលបរិច្ឆេទ(សំណុំរឿង3)

ផ្នែកដែល Y លើកឡើង
(ទទួលស្គាល់ ឬ មិនទទួលស្គាល់)



លក្ខខណ្ឌ1:ការបង្កើតកិច្ចសន្យាអាណត្តិ → ទទួលស្គាល់

លក្ខខណ្ឌ2:ការប្រគល់ប្រាក់ចំនួន១000ដុល្លារ → ទទួលស្គាល់

លក្ខខណ្ឌ3:មូលហេតុនៃការរំលោយ → មិនចាំបាច់ទទួលស្គាល់ ឬ មិនទទួលស្គាល់ឡើយ

លក្ខខណ្ឌ4:ការបង្ហាញឆន្ទៈអំពីការរំលោយ → ទទួលស្គាល់

# 3 ការបន្តចូលកាលបរិច្ឆេទ(សំណុំរឿង3)

## ផ្នែកដែលYបានលើកឡើង(ការតវ៉ា)



ខ្ញុំបានចរចាបន្ថែមជាមួយនឹងA ហើយបានទាមទារឲ្យA សងប្រាក់កម្ចីនោះ។ សោហ៊ុយសម្រាប់ចំណាយចំពោះការចរចានោះ ក៏កើតមានផងដែរ។

ការតវ៉ាអំពីការទូទាត់ដោយផ្អែកលើសិទ្ធិទាមទារសេវាការពារក្តី និង សិទ្ធិទាមទារឲ្យសងសោហ៊ុយដែលបានចំណាយ

# 3 ការបន្តចូលកាលបរិច្ឆេទ(សំណុំរឿង3)

ការបញ្ជាក់ឲ្យច្បាស់អំពី
ចំណុចវិវាទ



ពាក្យបណ្តឹង



ឯកសារចម្លើយ



លក្ខខណ្ឌ1：ការបង្កើតកិច្ចសន្យាអាណត្តិ ○
លក្ខខណ្ឌ2：ការប្រគល់ប្រាក់ចំនួន១000ដុល្លារ ○
លក្ខខណ្ឌ3：មូលហេតុនៃការរំលាយ －
លក្ខខណ្ឌ4：ការបង្ហាញឆន្ទៈអំពីការរំលាយ ○
ការតវ៉ា：ការតវ៉ាអំពីការទូទាត់(សិទ្ធិទាមទារលើប្រាក់សេវារឿងក្តី និង សិទ្ធិទាមទារឲ្យសងសោហ៊ុយដែលបានចំណាយ)
ចំណុចវិវាទគឺ

・ អត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិទាមទារលើប្រាក់សេវារឿងក្តីរបស់ Y
・ អត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិទាមទារឲ្យសងសោហ៊ុយដែលបានចំណាយរបស់ Y

# 4 សាលក្រម(សំណុំរឿង3)

## ឧទាហរណ៍ក្នុងករណីដែលដើមចោទបានឈ្នះក្ដី



សេចក្ដីសម្រេចបញ្ចប់

1. បង្គាប់ឲ្យចុងចម្លើយ Y បង់ប្រាក់១០០០ដុល្លារ និងបង់ការប្រាក់៥%ក្នុង១ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៧ (ថ្ងៃបន្ទាប់នៃថ្ងៃដែលបានបញ្ជូនពាក្យបណ្ដឹង)រហូតដល់ថ្ងៃសងរួច។
2. ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។
3. សាលក្រមនេះអាចអនុវត្តជាបណ្ដោះអាសន្នចំពោះចំណុចទី១។

# 4 សាលក្រម(សំណុំរឿង3)

ឧទាហរណ៍ក្នុងករណីដែលដើមចោទបានចាញ់ក្តី (ឧទាហរណ៍ដែលតុលាការទទួលស្គាល់ការតវ៉ាអំពីការទូទាត់(ចំនួន៥00ដុល្លារ) ដែល Y អះអាង)



សេចក្តីសម្រេចបញ្ចប់

1. បង្គាប់ឲ្យចុងចម្លើយ Y បង់ប្រាក់៥00ដុល្លារ និងបង់ការប្រាក់ ៥%ក្នុង១ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៧ (ថ្ងៃបន្ទាប់នៃថ្ងៃដែលបានបញ្ជូនពាក្យបណ្តឹង) រហូតដល់ថ្ងៃសងរួច។
2. ច្រានចោលការទាមទារក្រៅពីនេះរបស់ដើមចោទ X។
3. ប្រាក់ប្រដាប់ក្តីបែងចែកជា២ចំណែក ហើយជាបន្ទុករបស់ដើមចោទ និងចុងចម្លើយស្មើភាគគ្នា។
4. សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នបានចំពោះចំណុចទី១។

# Fin.

**The Legal and Judicial Development Project (Phase V)**

☞ https://www.jica.go.jp/project/english/cambodia/025/index.html

**The Legal and Judicial Development Project (Phase 4)**

☞ https://www.jica.go.jp/project/english/cambodia/014/index.html